# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧១...សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល



www.pheakdeylaw.com

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ដើម្បីដឹកនាំដំណើរការ និងអនុវត្តការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ហៅកាត់ គ.វ.ជ. ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ពេជ្រ ប៊ុនធិន** | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | ប្រធាន |
| ២. ឯកឧត្តម **យស់ ប៊ុនណា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងជាអនុប្រធានប្រចាំការគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | អនុប្រធានប្រចាំការ |
| ៣. ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. ឯកឧត្តម **ចាន់ សុធី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥. ឯកឧត្តម **អ៊ីន ធីរជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. ឯកឧត្តម **តែ គុយសេ៊ង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧. ឯកឧត្តម **ជោង ម៉ូរ៉ាន់** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. ឯកឧត្តម **ចាយ សាមិត្ត** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩. ឯកឧត្តម **យ៉េត ទីណៃល** | អគ្គលេខាធិការរងនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១០. ឯកឧត្តម **ចាន់ សុធា** | អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | សមាជិក |
| ១១. ឯកឧត្តម **ជ័យ សារិន** | អគ្គាធិការនៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២. លោកវេជ្ជបណ្ឌិត **ម៉ី សំអួរ** | ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងសុខាភិបាល | សមាជិក |
| ១៣. លោក **សៀត ទិចិត្រ** | ប្រធាននាយកដ្ឋានសេវាសាធារណៈ តំណាងលេខាធិការដ្ឋាន គ.ក.រ | សមាជិក |

សមាសភាពជាតំណាងនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃអគ្គនាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ត្រូវបំពេញមុខងារជាសមាជិកនៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ផ្អែកតាមករណីពាក់ព័ន្ធ។



www.pheakdeylaw.com

**ប្រការ២ .-**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ណែនាំ ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និង វិស័យសុខាភិបាល
- ផ្សព្វផ្សាយការដាក់ឱ្យអនុវត្តការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងឆ្នាំនីមួយៗ
- ណែនាំ ផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសដល់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ ហៅកាត់ថា គ.វ.ក. និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ហៅកាត់ថា គ.វ.រ. ឱ្យបំពេញការកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន
- រៀបចំឱ្យមានតារាងវាយតម្លៃនិងដាក់ពិន្ទុ ដើម្បីប្រើប្រាស់ជាមូលដ្ឋាននៃការពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ ក្នុងដំណាក់កាលនីមួយៗ របស់ គ.វ.ក. និង គ.វ.រ. តាមស្មារតីនៃអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- ធ្វើការពិនិត្យ វាយតម្លៃ និងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈ ដែលស្នើឡើងដោយ គ.វ.រ. ព្រមទាំងសម្រេចកំណត់ចំណាត់ថ្នាក់របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូចំនួន ១០(ដប់)ប្រចាំឆ្នាំ។ ការពិនិត្យនិងវាយតម្លៃរបស់ គ.វ.ជ. ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- ពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងដំណើរការនៃការពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ
- រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយអំពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ព្រមទាំងបទពិសោធន៍ និង ឧត្តមានុវត្តន៍ទាំងឡាយដែលគាំទ្រដល់ការកែលម្អដំណើរការរបស់អង្គភាពសាធារណៈ
- រៀបចំពិធីប្រកាសនិងផ្តល់រង្វាន់ប្រចាំឆ្នាំដល់អង្គភាពជ័យលាភី សិក្ខាសាលា សន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីលើកកម្ពស់និងបំផុសការយល់ដឹង និងស្មារតីនៃការប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។

**ប្រការ៣ .-**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង និងអាចប្រើប្រាស់មន្ត្រីរបស់ក្រសួង ស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ។



www.pheakdeylaw.com

**ប្រការ៤ ..**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិមកចូលរួមផ្តល់យោបល់ដើម្បីសម្រេចតួនាទីនិងភារកិច្ចដូចមានចែងក្នុងប្រការ២នៃសេចក្តីសម្រេចនេះ។

**ប្រការ៥ ..**

អនុប្រធានប្រចាំការ អនុប្រធាន សមាជិក និងលេខាធិការនៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ប្រធានអាចប្រគល់ភារកិច្ចដឹកនាំកិច្ចប្រជុំជូនអនុប្រធានប្រចាំការក្នុងករណីមានធុរៈ។

**ប្រការ៦ ..**

សមាជិកនៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេសអន្តរក្រសួង អាចប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័នសាមី ដើម្បីបំពេញបេសកកម្ម។

**ប្រការ៧ ..**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមុខងារសាធារណៈ។

**ប្រការ៨ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com